# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៥៦ គ.ជ.ប. ស.ជ.ណ

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ នេះ គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ចំនួន **៣.៣០៨រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត ដោយក្នុងមួយឃុំ សង្កាត់ ត្រូវជ្រើសរើសចំនួន **២រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

១- ប្រធានក្រុមចុះឈ្មោះបោះឆ្នោត ចំនួន ១ រូប

២- សមាជិកក្រុមចុះឈ្មោះបោះឆ្នោត ជាការីកុំព្យូទ័រ ចំនួន ១ រូប

សាធារណជនដែលមានបំណងដាក់ពាក្យសុំចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមសាលាឃុំ សង្កាត់ ឬ/និងទីសាធារណៈក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ លធ.ឃប ពាក់ព័ន្ធ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្តីជូនដំណឹងនេះ។

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ នៅតាមសាលាឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត
- ការប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤ នៅតាមមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌ។

ថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២៤

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ០៥៧ **គ.ជ.ប.** ស.ន.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## លក្ខខណ្ឌនៃការជ្រើសរើសសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ នេះ គ.ជ.ប ត្រូវការជ្រើសរើសសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ចំនួន **៣.៣០៤រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត ដោយក្នុងមួយឃុំ សង្កាត់ ត្រូវជ្រើសរើសចំនួន **២រូប** ដែលមានមុខតំណែងដូចខាងក្រោម ៖

១- ប្រធានក្រុមចុះឈ្មោះបោះឆ្នោត ក្នុងមួយឃុំ សង្កាត់ ចំនួន ១ រូប

២- សមាជិកក្រុមចុះឈ្មោះបោះឆ្នោត ជាការីកុំព្យូទ័រ ក្នុងមួយឃុំ សង្កាត់ ចំនួន ១ រូប

### I- លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាព ក.ច.ប មានដូចខាងក្រោម ៖

- មានសិទ្ធិបោះឆ្នោត ( មានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ )
- មានទីលំនៅក្នុងឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តនោះ
- មានឆន្ទៈបម្រើការងារក្នុងគោលជំហរអព្យាក្រឹត និងមិនលម្អៀង
- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ ឬសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- មិនមែនជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុង ក.ច.ប តែមួយ
- មានលទ្ធភាពបម្រើការងារពេញម៉ោង
- មានសុខភាពល្អ
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីមានពិការភាព ដែលមានសមត្ថភាព និងការយល់សម្បទាសមស្រប ឬបេក្ខជន និងបេក្ខនារី ដែលជាជនជាតិដើមភាគតិចប្រសិនបើមាន។

**II- លក្ខខណ្ឌបច្ចេកទេសដែលទាមទារ ដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ៖**

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានចំណេះដឹងប្រហាក់ប្រហែល ដែលទាក់ទងជាមួយមុខតំណែង
- មានការយល់ដឹង ឬ/និងចេះប្រើប្រាស់កុំព្យូទ័រកាន់តែប្រសើរ
- ចំពោះមុខតំណែងជាសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ត្រូវមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធអ៊ីនធឺណិតជាចាំបាច់។

**III- តួនាទី និងភារកិច្ចរួមរបស់ ក.ច.ប**

- គោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ (ប.ន.ព.ច)
- ប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យល់ដឹងច្បាស់លាស់ និងចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព
- ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់
- អនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញក្នុងការចុះឈ្មោះបោះឆ្នោត ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- សហការជាមួយ លធ.ខប ដើម្បីអនុវត្តនីតិវិធីលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ឬសហការជាមួយ លធ.ខប និង កបឃ.ស ដើម្បីជូនដំណឹងដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឱ្យមកបំពេញលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត
- រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដែលទទួលបានក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត
- ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងជំពូកទី៤ នៃ ប.ន.ព.ច
- ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយណាដែលបង្កការរំខាន ឬ/និងរំលោភបំពាន លើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកចុះឈ្មោះបោះឆ្នោត លើកលែងតែមានការអនុញ្ញាតដូចមានចែងក្នុង ប.ន.ព.ច ។ ការរំខាន ឬ/និងការរំលោភបំពាន មានជាអាទ៍ ៖

- ការកត់ត្រា ឬការថតយកទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតពីកុំព្យូទ័រ
- ការកត់ត្រា ឬការថតឯកសាររបស់អ្នកសុំចុះឈ្មោះបោះឆ្នោត នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ការព្យាយាមតាមគ្រប់មធ្យោបាយផ្សេងទៀតដើម្បីកត់ត្រា ឬថតឯកសារ ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

**IV- រយៈពេលបម្រើការងារ**

ចាប់ផ្តើមចូលបម្រើការងារពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ ។

**V- ប្រាក់កម្រៃ**

- ប្រធាន ក.ច.ប ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- សមាជិក ក.ច.ប ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.២០០.០០០ រៀល។

**VI- ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមសាលាឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប អាសយដ្ឋាន (www.nec.gov.kh) ឬស្កេន QR-Code ដូចមានក្នុងសេចក្តីជូនដំណឹងតាមប្រព័ន្ធផ្សព្វផ្សាយ។

**VII- កាលបរិច្ឆេទនៃការចែកពាក្យ និងទទួលពាក្យ និងការប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ**

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ ( វេលាម៉ោង ១៧:៣០ នាទីល្ងាច )
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ នៅតាមសាលាឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត
- ការប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤ នៅតាមមណ្ឌលប្រមូលផ្តុំ ក្រុង ស្រុក ខណ្ឌ។

ចំពោះមុខតំណែងប្រធាន ក.ច.ប ត្រូវធ្វើការប្រឡង QCM ហើយមុខតំណែងសមាជិក ក.ច.ប ជាការីកុំព្យូទ័រត្រូវប្រឡងតាមរយៈការធ្វើតេស្តកុំព្យូទ័រ។

**VIII- ការអនុវត្តបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

អនុគណៈកម្មការចែកពាក្យ ទទួលពាក្យ និងរៀបចំការប្រឡងតាមក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជន និងត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេ ៣រូប ក្នុងមួយមុខតំណែង មកប្រឡង QCM និងធ្វើតេស្តកុំព្យូទ័រ។ លទ្ធផលនៃការប្រឡងជ្រើសរើសត្រូវដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច និងតែងតាំង។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវប្រគល់ជូនវិញទេ។

**IX- លទ្ធផលនៃការប្រឡងជ្រើសរើស**

លទ្ធផលនៃការប្រឡងជ្រើសរើសនឹងបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ចំណុះរាជធានី ខេត្ត។

**<u>បញ្ជាក់បន្ថែម</u>** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល »
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់ ៚

ថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ